# សហគមន៍ខ្មែរក្រោម រម្លឹកខួបបាត់ដីកម្ពុជាក្រោមទៅឲ្យវៀតណាម

TUESDAY 04 JUNE B.E.2557 A.D.2013

*ភ្នំពេញប៉ុស្តិ៍*




ពិធីរម្លឹកខួប ៦៤ឆ្នាំ ៤ មិថុនា ១៩៤៩ ជាថ្ងៃដែលអាណានិគមបារាំងកាត់ទឹកដីខ្មែរកម្ពុជាក្រោម។ រូបថត ហុង មិនា

**ភ្នំពេញ:** ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរប្រមាណជាង ១ពាន់អង្គនិងនាក់ បានជួបជុំគ្នានៅសហគមន៍បុរីព្រៃនគរ ក្នុងខណ្ឌសែនសុខ ដើម្បីទាមទារសិទ្ធិនិងរម្លឹកខួប ៦៤ឆ្នាំ ៤ មិថុនា ១៩៤៩ ជាថ្ងៃដែលអាណានិគមបារាំងកាត់ទឹកដីខ្មែរកម្ពុជាក្រោមចំនួន ២០ខេត្ត និងពលរដ្ឋរាប់លាននាក់ឲ្យទៅអាណានិគមវៀតណាមគ្រប់គ្រង។

ចាប់តាំងពីព្រឹកថ្ងៃអង្គារនេះ បទចំរៀងដែលរៀបរាប់ពីការបាត់បង់ទឹកដី ការឈឺចាប់និងគំរាមកំហែងបំបិទសិទ្ធិសេរីភាពពីសំណាក់អាជ្ញាធរវៀតណាមមកលើពលរដ្ឋខ្មែរក្រោមត្រូវបានគេចាក់ ដើម្បីស្វាគមន៍ដំណើរមកដល់របស់អ្នកចូលរួមដែលភាគច្រើនជាព្រះសង្ឃ។

រូបថតធំៗបីសន្លឹករបស់ព្រះសង្ឃ និងវីរៈបុរសខ្មែរដែលបានបូជាព្រះកាយនិងជីវិតដើម្បីការពារទឹកដីកម្ពុជាក្រោម ត្រូវបានគេដាក់រួមគ្នានៅលើតុមួយដើម្បីគោរពព្រះវិញ្ញាណក្ខន្ធ។ លើសពីនោះ រូបថតជាង ១០០ សន្លឹកផ្សេងទៀតនៅលើបដាដែលនិយាយពីសកម្មភាពតវ៉ា ការចាប់ចង ការកាត់ទោសព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមពីសំណាក់អាជ្ញាធរវៀតណាម ក៏ត្រូវបានគេដាក់បង្ហាញជាសាធារណៈផងដែរ។

Courtesy The Phnom Penh Post